ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
៩៤២ ឧរថ. ករដក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់សំរាប់មន្ត្រី នៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែ នៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ ១.:**

បង្កើត និងកំណត់ឯកសណ្ឋាន និងផ្លាកសញ្ញាសំគាល់សំរាប់មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ប្រើប្រាស់នៅពេលបំពេញការងារ ក្នុងការិយាល័យ ចុះត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងបំពេញការងារនៅតាមការដ្ឋានអាជីវកម្មធនធានរ៉ែ ។

**ប្រការ ២.:**

ឯកសណ្ឋានសំរាប់មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុងត្រូវបានកំណត់ដូចខាងក្រោម៖

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ក. ឯកសណ្ឋានសំរាប់បុរស :

- អាវ: ដៃខ្លី ថ្នេរវាយ និងកបើក ធ្វើអំពីសាច់ក្រណាត់ពណ៌កាគីលឿងចាស់ ឡេវពីមុខពណ៌ដូចអាវ មានប៉ូលស្មាទាំងសងខាង ហើយសំរុងជើងអាវត្រង់ស្មើ វែកពីក្រោយសងខាងតាមបណ្តោយដងខ្លួនប្រវែង ២៥ ស.ម។ អាវនេះមានហោប៉ៅខាងលើពីរ និងខាងក្រោមពីរ (ដេរប៉ះ) មានគំរបហោប៉ៅរាងស្លឹកពោធិ៍ និងដាក់ឡេវជ័រពណ៌ដូចអាវ ហើយមានដេរជាផ្នត់ទំហំប្រហែល ៣ ស.ម ពុះចំពាក់កណ្តាលហោប៉ៅ ។
- ខោ: ជើងវែងធ្វើអំពីសាច់ក្រណាត់ពណ៌ទឹកប៊ិចចាស់ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅខាងក្រោយមួយដេរបង្កប់ មានគំរបរាងស្លឹកពោធិ៍ ចោះរន្ធដាក់ឡេវចំនួន១ និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្នេរ ។
- ស្បែកជើង: ស្បែកជើងកខ្លី ធ្វើអំពីស្បែក មានពណ៌ខ្មៅ ចងខ្សែ ឬស៊ក។
- ខ្សែក្រវ៉ាត់: ខ្សែក្រវ៉ាត់ធ្វើអំពីស្បែក មានពណ៌ខ្មៅ ។

ខ. ឯកសណ្ឋានសំរាប់នារី :

- អាវ: ដៃខ្លី ថ្នេរវាយនិងកបើក ធ្វើអំពីសាច់ក្រណាត់ពណ៌កាគីលឿងចាស់ ឡេវពីមុខពណ៌ដូចអាវ មានប៉ូលស្មាទាំងសងខាង ហើយសំរុងជើងអាវត្រង់ស្មើ ជីបរាង។ អាវនេះមានហោប៉ៅខាងលើពីរ និងខាងក្រោមពីរ (ដេរប៉ះ) មានគំរបហោប៉ៅរាងស្លឹកពោធិ៍ និងដាក់ឡេវជ័រពណ៌ដូចអាវ ហើយមានដេរជាផ្នត់ទំហំប្រហែល ៣ ស.ម ពុះចំពាក់កណ្តាលហោប៉ៅ។
- សំពត់: សំពត់ហ្សីបធ្វើអំពីសាច់ក្រណាត់ពណ៌ទឹកប៊ិចចាស់ មានសំរុងក្រោមជង្គង់ ។
- ស្បែកជើង: ស្បែកជើងអេស្កាប៉ាង់ ធ្វើអំពីស្បែក មានពណ៌ខ្មៅ ។

ប្រការ ៣.:

ផ្លាកសញ្ញា និងផ្លាកឈ្មោះសំរាប់សំគាល់មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

ក. ផ្លាកសញ្ញា និងផ្លាកឈ្មោះសំរាប់សំគាល់មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ

- ផ្លាកសញ្ញានៅលើដៃអាវខាងស្តាំ

ផ្លាកសញ្ញានៅលើដៃអាវខាងស្តាំ គឺជាផ្លាកសញ្ញារបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ធ្វើអំពីក្រណាត់ក្រាស់ មានរាងជារង្វង់ដែលមានអង្កត់ផ្ចិតប្រវែង ៨ ស.ម និងពាសដោយផ្ទៃពណ៌ទឹកប៊ិចចាស់ ។ នៅលើផ្ទៃពណ៌សផ្នែកខាងក្នុងផ្លាកសញ្ញា មានសរសេរអក្សរខ្មែរមូលពណ៌ទឹកប៊ិចនៅតាមខ្សែកោងនៃរង្វង់ភាគខាងលើនូវពាក្យថា "ព្រះរាជាណាចក្រកម្ពុជា" ហើយនៅពីក្រោមអក្សរនេះមានសរសេរអក្សរធំជាភាសាអង់គ្លេសពណ៌ដូចអក្សរខ្មែរ នូវពាក្យថា "KINGDOM OF CAMBODIA" ។ រីឯនៅផ្នែកខាងក្រោមនៃផ្លាកសញ្ញាមានសរសេរអក្សរខ្មែរ និងអក្សរអង់គ្លេសតូចៗពណ៌ទឹកប៊ិច នូវពាក្យថា "ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល" និង "MINISTRY OF INDUSTRY, MINES AND ENERGY" នៅតាមខ្សែកោងនៃរង្វង់ ។ នៅចំកណ្តាលនៃផ្លាកសញ្ញាមានរង្វង់មួយទៀតមានអង្កត់ផ្ចិតប្រវែង ៦ ស.ម ពាសដោយផ្ទៃពណ៌ទឹកប៊ិចចាស់ និងរំលេចដោយរូបរោងចក្រពណ៌ប្រផេះលាយខ្មៅ បង្គោលខ្សែភ្លើងពណ៌ខ្មៅ ទូដឹករ៉ែពណ៌លឿងលាយខ្មៅ និងស្លឹមម៉ាស៊ីនពណ៌លឿង ។

- ផ្លាកសញ្ញាសំរាប់ពាក់ជាប់កអាវ

ផ្លាកសញ្ញានេះមានរូបញញួរនិងប៉ែលដាក់ខ្វែងគ្នាជាសញ្ញាលេខបួក និងមានពណ៌ទឹកមាស ។

- ផ្លាកឈ្មោះ

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំមានរាងចតុកោណកែងបណ្តោយប្រវែង៩.៥ស.ម និងទទឹងប្រវែង ២ ស.ម ធ្វើអំពីស្ពាន់ដែលមានពណ៌ទឹកមាស និងពាសដោយជ័រឹងថ្លា មានផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ ០.១៥ ស.ម។ នៅលើផ្លាកឈ្មោះផ្នែកខាងស្តាំ មានផ្លាកសញ្ញារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលមានអង្កត់ផ្ចិតប្រវែង ១.៧ ស.ម។ នៅខាងឆ្វេង នៃផ្លាកសញ្ញារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានសរសេរអក្សរឡាតាំងជាពីរជួរដែលជួរខាងលើ សរសេរនាមត្រកូល និងនាមខ្លួនរបស់មន្ត្រី និងជួរខាងក្រោមសរសេរអត្តលេខរបស់មន្ត្រី។

ខ. ផ្លាកសញ្ញានិងផ្លាកឈ្មោះសំរាប់សំគាល់មន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង :

- ផ្លាកសញ្ញាពាក់នៅលើដៃអាវខាងស្តាំ

ផ្លាកសញ្ញានៅលើដៃអាវខាងស្តាំគឺជាផ្លាកសញ្ញារបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ធ្វើអំពីក្រណាត់ក្រាស់ រាងជារង្វង់មានអង្កត់ផ្ចិតប្រវែង ៨ ស.ម និងពាសដោយផ្ទៃពណ៌ស និងពណ៌ទឹកប៊ិចចាស់។ នៅលើផ្ទៃពណ៌សផ្នែកខាងក្នុងផ្លាកសញ្ញា មានសរសេរអក្សរខ្មែរមូលពណ៌ទឹកប៊ិចនៅតាមខ្សែស្របនៃរង្វង់ភាគខាងលើ នូវពាក្យថា "ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល" និងនៅផ្នែកខាងក្រោមនៃរង្វង់ដូចគ្នានេះមានសរសេរអក្សរខ្មែរមូល នូវពាក្យថា " មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត..."។ ចំណែកនៅចំកណ្តាលនៃផ្លាកសញ្ញាមានរង្វង់មួយដែលមានអង្កត់ផ្ចិតប្រវែង ៥ ស.ម ពាសដោយផ្ទៃពណ៌ទឹកប៊ិចចាស់ និងរំលេចដោយរូបរាងចក្រពណ៌ប្រផេះលាយខ្មៅ បង្គោលខ្សែភ្លើងពណ៌ខ្មៅ ឡដឹករ៉ែពណ៌លឿងលាយខ្មៅ និងស្តីមាស៊ីនពណ៌លឿង។

- ផ្លាកសញ្ញាសំរាប់ពាក់ជាប់កអាវ

ផ្លាកសញ្ញានេះមានរូបញញួរនិងប៉ែលដាក់ខ្វែងគ្នាជាសញ្ញាលេខបូក និងមានពណ៌ទឹកមាស ។

- ផ្លាកឈ្មោះ

ផ្លាកឈ្មោះសំរាប់ពាក់នៅលើហោប៉ៅអាវខាងស្តាំ មានរាងចតុកោណកែងបណ្តោយប្រវែង ៩.៥ ស.ម និងទទឹងប្រវែង ២ ស.ម ធ្វើអំពីស្ពាន់ដែលមានពណ៌ទឹកមាស និងពាសដោយជ័រឹងថ្លា មានផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ស្តើងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ ០.១៥ ស.ម។ នៅលើផ្លាកឈ្មោះផ្នែកខាងស្តាំមានផ្លាកសញ្ញារបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដែលមានអង្កត់ផ្ចិតប្រវែង ១.៧ ស.ម ។ នៅខាងឆ្វេងនៃផ្លាកសញ្ញារបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង មានសរសេរអក្សរឡាតាំងជាពីរជួរដែល ជួរខាងលើសរសេរនាមត្រកូលនិងនាមខ្លួនរបស់មន្ត្រី និងជួរខាងក្រោមសរសេរ អត្តលេខរបស់មន្ត្រី។

## ប្រការ ៤.:

មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវបានផ្តល់ជូននូវឯកសណ្ឋានពីរសម្រាប់ក្នុងមួយឆ្នាំ ដើម្បីប្រើប្រាស់សំរាប់បំពេញការងារក្នុងការិយាល័យ ចុះត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងបំពេញការងារនៅតាមការដ្ឋានអាជីវកម្មធនធានរ៉ែ ។

## ប្រការ ៥.:

ជនណាក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន និងផ្លាកសញ្ញាសំរាប់សំគាល់មន្ត្រីនៃអគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ត្រីធនធានរ៉ែនៃមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដូចមានចែងក្នុងប្រការ ២ និងប្រការ ៣ ខាងលើ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។/

ប្រការ ៦.:

អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ ប្រធាននាយកដ្ឋានចំណុះអគ្គនាយកដ្ឋានធនធានរ៉ែ នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល គ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចំលងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៦
- ឯកសារកាលប្បវត្តិ